# ទស្សនវិជ្ជា ជាអ្វី?

ទស្សនវិជ្ជាជាអ្វី**?** ភាសាបារាំងថា philosophie = philo+ sophieដែលមានន័យថា ស្រលាញ់ + គតិបណ្ឌិត។ ប៉ុន្តែតាមការបកប្រែក្នុងវចនានុក្រមរបស់សម្តេចសង្ឃជួន ណាត ប្រែថា ៖ វិជ្ជាដែលកើតឡើងដោយទស្សនៈ ' , វិទ្យាសាស្ត្រថែងអំពីគោលការសំខាន់ៗនិងឬព្វហេតុ ផ្សេងៗឬអំពីជិវិតសត្វនិងមនុស្ស។តាមការបកប្រែជាភាសាខ្មែរពីតជាមានការឆ្លងពីន័យដើម នៃពាក្យ philosophie ដែល មានដើមកំណើតយ៉ាងប្រាកដឡើងនៅប្រទេសក្រិកបុរាណ ក្នុងសតវត្សទីប្រាំ មុនគ្រឹស្តសករាជ។តើទស្សនវីជ្ជាជាវិជ្ជាដែលកើត ចេញមកពីទស្សនៈ? ឬក៏ទស្សនៈកើតចេញមកពីវិជ្ជា? ឬក៏ជាវិជ្ជាដែលបង្រៀនអំពីទស្សនៈ? ទស្សនៈផ្សេងៗរបស់អ្នកប្រាជ្ញ? កាលដែលខ្មែរយើង ប្រែពាក្យ philosophieថា ទស្សនវិជ្ជា ដូចជាមិនទំនងទេ ព្រោះបើពិនិត្យមើលន័យដើមរបស់ពាក្យនោះគឺខុសគ្នា...ចឹងយើងថាscience des opinions ឬ science des points de vue ក៏បានដែរ ព្រោះថា science=វិជ្ជា រីឯopinions ប្រែថា មតិ ឬ ទស្សនៈ។ ទោះបីយ៉ាងណា ទស្សនវិជ្ជា ក៏យើងអាចយល់ន័យបានដែល ពីព្រោះទស្សនវិជ្ជាជាវិជ្ជាមួយដែលបង្រៀនសិស្សអោយសិក្សាគំនិត ឬ ទស្សនៈផ្សេងៗ របស់អ្នកប្រាជ្ញបណ្ឌិតនានាក្នុងលោកដែលមានមិនដូចគ្នា ទៅតាមជំនឿ រឺ ការយល់ដឹងនៃទស្សនវិទូម្នាក់ៗ។តាមដោយពិត philosophieគឺបង្កប់ន័យយ៉ាងត្រឹមត្រូវអំពីការស្រលាញ់ ឬចូលចិត្ត គតិបណ្ឌិតដែលជាប្រាជ្ញាញាណរបស់អ្នកប្រាជ្ញ ហើយពាក្យហ្នឹងពិតជាបានចាប់កំណើតចេញមកពីប្រទេសក្រិកបុរាណដែលកកើតទស្សនៈវិទូមុនគេ ហើយដែលមានទស្សនវិទូគឺលោក ប្លា តុង(Platon) ដែលជាមហាទស្សនៈវិទូមានកត្តិនាមល្បីល្បាញ កោតសរសើរនិងគោរពជាងគេទាំងអស់ក្នុងបណ្តាទស្សនវិទូទាំងឡាយនៅបស្ចិមប្រទេស។ទស្សនវិទូ និងអ្នកគណិតសាស្ត្រអង់គ្លេសម្នាក់ឈ្មោះ Alfred Northwhiteheadបាននិយាយពីលោកប្លាតុងថាប្រវត្តិសាស្ត្រនៃទស្សនវិជ្ជាបស្ចិមប្រទេសគ្រាន់តែជាសេរីលេខយោង(footnote)ទៅនឹងលោកប្លាតុងតែប៉ុណ្ណោះ។ចំណែកឯករី និងទស្សនវិទូ Ralph Waldo Emersonបាននិយាយពីលោកប្លាតុងថា ៖ប្លាតុង គឺ ទស្សនវិជ្ជា ហើយទស្សនវិជ្ជា គឺប្លាតុង( Plato is Philosophy ,and philosophy Plato.)ហើយថាចេញពីលោកប្លាតុង គឺរឿងរ៉ាវទាំងអស់ដែលនៅតែត្រូវបានសរសេរនិងពិភាក្សាក្នុងចំណោមអ្នកប្រាជ្ញ។

ចឹងចង់ដឹងណាស់ថា ទស្សនវិជ្ជា មានដើមកំណើតយ៉ាងម៉េច? ដើម្បីអ្វី? ហេតុអ្វីស្រលាញ់ទស្សនវិជ្ជា?មានអាថ៌កំបាំងអ្វីដែលនាំអោយទស្សនវិជ្ជាត្រូវបានអ្នកប្រាជ្ញទាំងឡាយក្នុងលោករស្រលាញ់រាប់អាន? ឬក៏ថាទស្សនវិជ្ជាជាដំណើរការនៃការស្វែងរក ការពិត ?តាមពិត ទស្សនវិជ្ជាមិនមែនត្រឹមតែជាដំណើរការស្វែងរកការពិត ប៉ុណ្ណោះទេ ថែមទាំងជាការត្រូវរស់នៅក្នុងការពិតទៀត។ដូច្នេះ ទស្សនវិទូទាំងអស់ យល់ឃើញការពិតហើយ ត្រូវតែរស់ក្នុងការពិតផងដែរ ទើបមានឈ្មោះថាទស្សនវិទូ តួយ៉ាងដូចជាលោកសូក្រាត ការដែលបានយល់ដឹងការពិតយ៉ាងណាហើយលោកបញ្ចូលជីវិតលោកក្នុងការពិតនោះទៀត..មិនមាននរណាអាចបង្វែងលោកចេញពីគំនិតយល់ឃើញរបស់លោកបានឡើយ..លោកត្រូវរស់ជាមនុស្សសាមញ្ញបំផុតម្នាក់ដែលអោយភាពគ្មានតំលៃអ្វីសំខាន់ចំពោះជីវិតនូវរបស់ទាំងឡាយណាដែលលោកមើលឃើញថាបានត្រឹមតែបំរើចក្ខុ គ្រាន់តែល្អមើល តែមិនបានចិញ្ចឹមជីវិតដូចឃ្លាមួយលោកបានពោលខ្លួនឯងឡើងពេលកំពុងសំលឹងមើលគំនរឥវ៉ាន់ដែលគេលក់ដូរនៅទីផ្សារយ៉ាងដូច្នេះ៖តើមានរបស់របរប៉ុន្មានទៅ ដែលខ្ញុំអត់ត្រូវការទាល់តែសោះ**?**លោកឱស្សាហ៍សូត្រកាព្យមួយដូចនេះ ៖គ្រឿងតុបតែងពណ៌ក្រហមនឹងប្រាក់បំរើសំរាប់សំដែងល្ខោនតែមិនសំរាប់ចិញ្ចឹមជីវិតឡើយ។ប៉ុន្តែ ទស្សនវិជ្ជា ទោះបីថាជាការស្វែងរកការពិតចឹងមែនហើយ តែមិនបានន័យថាមានការពិតជាកម្មសិទ្ធនោះទេហើយដោយហេតុថា ទស្សនវិទូមានន័យថាជាអ្នកស្រឡាញ់រាប់អានការពិត ដូច្នេះជាអ្នកដែលមិនចាំបាច់ជាមនុស្សមានវិជ្ជានោះទេ philosophe est ,par opposition à celui qui possédant le savoir qui se nomme savant, nommé aimant du savoir ដែលប្រែថា ទស្សនវិទូ ផ្ទុយពីអ្នកដែលមានចំណេះដឹង ដែលគេហៅថាអ្នកប្រាជ្ញ,មាននាមថា អ្នកដែលស្រលាញ់ចំណេះដឹង។ប៉ុន្តែតាមការយល់ដឹងពីមនុស្សភាគច្រើន បែរជាថាទស្សនវិទូគឺជាអ្នកប្រាជ្ញា មានចំណេះដឹងជ្រៅជ្រះ មានទ្រឹស្តីល្អត្រឹមត្រូវដែលគួររៀនសូត្រតាម។មិនអញ្ចឹង,ទស្សនវិជ្ជា គឺជាការស្រលាញ់ចំណេះដឹង ការស្រលាញ់គតិបណ្ឌិតដែលមនុ-ស្ស ទាំងចាស់ទាំងក្មេងអាចរៀនបាន អាចរាប់អានឬស្រលាញ់ចូលចិត្ត គ្មានកំណត់ព្រំដែន។ តាមការបកប្រែពីវចនានុក្រមអង់គ្លេសមួយថាទស្សនវិជ្ជាគឺជាការស្រាវជ្រាវរកចំណេះដឹង...

ជាពិសេសអំពីលក្ខណៈនិងអត្ថន័យនៃជីវិត  តែក៏មានន័យមួយទៀតដែរថាជាប្រព័ន្ធនៃការស្វែរកចំណេះដឹង ដូចគេថាមនុស្សម្នាក់នេះ គ្មានតស្សនវិជ្ជាសោះ!ដែលមានន័យថាមិនមានដំរេះអំពីប្រព័ន្ធខាងលើហ្នឹង។ក្នុងវចនានុក្រមបារាំងមួយបានបកន័យថាទស្សនវិជ្ជាគឺជាសាខាមួយនៃវិជ្ជាឬចំណេះដឹងដែលសិក្សាអំពីគោលការណ៏និងហេតុផលនិងគោលការណ៏នៃសិលធម៌។ន័យមួយទៀតថា ជាការស្រាវជ្រាវនៃគោលការណ៏ដែលនាំបង្កើតបានវិទ្យាសាស្រ្ត។